# ព្រះរាជក្រម

នស/រកម/០៨១១/០១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលរដ្ឋសភាបានកែតម្រូវ នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានប្រកាសជម្រាបជូនអង្គប្រជុំព្រឹទ្ធសភា នាថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១១ ដោយយល់ឃើញថាគ្មានចំណុចអ្វីថ្មីដែលគួរផ្តល់យោបល់ឡើងវិញជាលើកទី២ឡើយ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ១១៨/០០៦/២០១១ កបធ.ច ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# ច្បាប់

# ស្តីពី

# វិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ

**មាត្រាមួយ.–**

ត្រូវបានបន្ថែមមាត្រា ១០ ស្ទួនកែប្រែមាត្រា ១៦ និងលុបមាត្រា ៥៧ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ ២០១០ ដូចខាងក្រោមៈ

**មាត្រា ១០.–ស្ទួន ប្រកាសរបស់ប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ**

ប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ចេញប្រកាសក្នុងការរៀបចំរចនាសម្ព័ន្ធរបស់អង្គភាពប្រឆាំងអំពើពុករលួយ ចាប់ពីថ្នាក់ក្រោមនាយកដ្ឋាន និងការតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ចមន្ត្រីក្របខណ្ឌស្ថាប័នប្រឆាំងអំពើពុករលួយចាប់ពីថ្នាក់ក្រោមប្រធាននាយកដ្ឋាន តាមសំណើរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ។

**មាត្រា ១៦.–ថ្មី ថវិកា និងធនធានរបស់ស្ថាប័នប្រឆាំងអំពើពុករលួយ**

ស្ថាប័នប្រឆាំងអំពើពុករលួយមានកញ្ចប់ថវិកាដោយឡែកសម្រាប់ដំណើរការការងាររបស់ខ្លួន ដែលស្ថិតនៅក្នុងថវិការរបស់ជាតិ ។ ស្ថាប័នប្រឆាំងអំពើពុករលួយ ទទួលធនធានចាំបាច់នានាពីរាជរដ្ឋាភិបាល និងមានសិទ្ធិទទួលនូវអំណោយ ឬ ជំនួយពីអង្គការជាតិ អន្តរជាតិនានា ។ ស្ថាប័នប្រឆាំងអំពើពុករលួយ មិនត្រូវទទួលជំនួយណាដែលនាំឲ្យមានទំនាស់ផលប្រយោជន៍ ។

ប្រធានអង្គភាពប្រឆាំងអំពើពុករលួយជាអាណាប័កដើមខ្សែ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ការគ្រប់គ្រងនិងចាត់ចែងថវិការបស់ស្ថាប័នប្រឆាំងអំពើពុករលួយ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥៧ ត្រូវបានលុបចោល ។

**មាត្រា ពីរ.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នសរកម. ១១០៧.០៣៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយ

**ហត្ថលេខា**

**ឱម យ៉ិនទៀង**

លេខ:៦៩៣ ប.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០១១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ចិនអេន**